**ព្រះរាជក្រម**

នស/រកម/០១៩៦/០២

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី៥ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់
# ស្តីពី
# ការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

មាត្រា១.-

ត្រូវបានបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈចំណុះរាជរដ្ឋាភិបាលកម្ពុជា។

មាត្រា២.-

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យវប្បធម៌ និង វិចិត្រសិល្បៈ នៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា៣.-

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអមដោយរដ្ឋលេខាធិការ និង ឬអនុរដ្ឋលេខាធិការតាមការចាំបាច់។

មាត្រា៤.-

ការរៀបចំរចនាសម្ព័ន្ធ និង ការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៥.-

បទបញ្ញត្តិទាំងឡាយដែលផ្ទុយនិងច្បាប់នេះត្រូវទុកជានិរាករណ៍។

មាត្រា ៦.-

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦

ព្រះហស្តលេខា

**នរោត្តម សីហនុ**

លេខច ០៦ ៖ .ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៩៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

**ណាឌី តាន់**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៦៣

## ស្តីពី

## ប្រព័ន្ធមត៌កមនុស្សរស់ នៃព្រះរាជាណាចក្រកម្ពុជា

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៦/០០៣ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦

ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីការការពារបេតិកភណ្ឌវប្បធម៌អរូបី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៩ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគី នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការការពារ និង ការលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២២ ខែមករា ឆ្នាំ ២០១០

## ត្រាស់បង្គាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ព្រះរាជក្រឹត្យនេះ មានគោលដៅកំណត់អំពីប្រព័ន្ធមត៌កមនុស្សរស់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ព្រះរាជក្រឹត្យនេះមានគោលបំណងដូចតទៅ ៖

- ធានាបាននូវការថែរក្សា និងការពារបេតិកភណ្ឌវប្បធម៌ជាតិឱ្យបានគង់វង្សទៅអនាគត
- គាំពារ និងលើកកម្ពស់ធនធានមត៌កមនុស្សរស់នៅទូទាំងប្រទេស ដោយបង្កើតជាយន្តការសម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌ជាតិ និងការអភិវឌ្ឍចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេសឱ្យមាននិរន្តរភាព បង្កើតប្រព័ន្ធសម្រាប់បន្តវេន និង ផ្ទេរចំណេះដឹង ជំនាញ ទេពកោសល្យ និង បច្ចេកទេស ផ្នែកបេតិកភណ្ឌវប្បធម៌អរូបីទៅជំនាន់ក្រោយ
- បង្កើនកិច្ចសហប្រតិបត្តិការរវាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងសាធារណជន អង្គការ

ជាតិ អន្តរជាតិ ដើម្បីជានាការអភិរក្ស និង ការអភិវឌ្ឍបេតិកភណ្ឌវប្បធម៌ជាតិ ជាពិសេសបេតិកភណ្ឌវប្បធម៌អរូបី។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះ មានវិសាលភាពអនុវត្តលើប្រជាពលរដ្ឋខ្មែរទាំងអស់។

**មាត្រា ៤.-**

វាក្យសព្ទដែលប្រើក្នុងព្រះរាជក្រឹត្យនេះ មាននិយមន័យដូចខាងក្រោម ៖

- មត៌កមនុស្សរស់ សំដៅដល់បុគ្គល ឬ ក្រុមមនុស្សមានចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេសកម្រិតខ្ពស់បំផុត ដែលចាំបាច់ដល់ការបង្កើតភាពសម្រិតសម្រាំងនៃទិដ្ឋភាពជីវិតវប្បធម៌របស់ប្រជាជន និងអត្ថិភាពបន្តនូវបេតិកភណ្ឌវប្បធម៌អរូបីរបស់ជាតិ។
- ប្រព័ន្ធមត៌កមនុស្សរស់ សំដៅដល់កន្សោមយន្តការគ្រប់គ្រងមត៌កមនុស្សរស់ តាមបទបញ្ញត្តិច្បាប់។

## ជំពូកទី២
## ការជ្រើសរើស និងការទទួលស្គាល់មត៌កមនុស្សរស់

**មាត្រា ៥.-**

មត៌កមនុស្សរស់ត្រូវជ្រើសរើស និង ទទួលស្គាល់ចេញពីទម្រង់ផ្សេងៗ នៃបេតិកភណ្ឌវប្បធម៌អរូបីដែលមាន លក្ខខណ្ឌដូចខាងក្រោម៖

- មានតម្លៃលេចធ្លោ និង ជាសក្ខីភាពនៃទេពកោសល្យដ៏ប៉ិនប្រសប់ក្នុងការបង្កើត និង ការច្នៃប្រឌិតតាមឯកទេសនីមួយៗ ដែលជាឫសគល់នៃប្រពៃណី និង វប្បធម៌របស់សង្គម
- មានចរិតលក្ខណៈបង្ហាញតម្លៃឯកនៃបេតិកភណ្ឌវប្បធម៌អរូបីក្នុងតំបន់ និងសហគមន៍
- មានសារៈសំខាន់ដែលអាចបញ្ជាក់ពីអត្តសញ្ញាណនៃតំបន់សម្រាប់ប្រជាពលរដ្ឋ និងសង្គមជាតិ។

លក្ខខណ្ឌទាំងបីខាងលើ ត្រូវយកមកពិចារណាដោយផ្តល់អាទិភាពនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម ៖

- ប្រឈមនឹងការថយចុះនៃអ្នកមានចំណេះដឹង ជំនាញ ទេពកោសល្យ និង បច្ចេកទេសដែលកំពុងទទួលរងឥទ្ធិពលអវិជ្ជមាននៃសកលភាវូបនីយកម្ម
- ប្រឈមនឹងការបាត់បង់នូវសារៈសំខាន់នៃលក្ខណៈដើម

- ប្រឈមនឹងការបាត់បង់នូវកិត្យានុភាពវប្បធម៌។

**មាត្រា ៦.-**

បុគ្គល ឬ ក្រុមមនុស្សណាមួយដែលត្រូវបានជ្រើសរើសជាមត៌កមនុស្សរស់ ត្រូវមានគ្រប់លក្ខណៈសម្បត្តិដូចខាងក្រោម ៖

- មានចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេស ស្នាដៃឯក ផ្នែកបេតិកភណ្ឌវប្បធម៌អរូបី
- មានមនសិការខ្ពស់ក្នុងការចូលរួមអភិរក្សបេតិកភណ្ឌវប្បធម៌អរូបី
- មានសមត្ថភាពខ្ពស់ក្នុងការផ្ទេរចំណេះដឹងដោយមិនលាក់លៀមវិជ្ជាជីវៈ ជំនាញ ទេពកោសល្យ និង បច្ចេកទេសទៅអ្នកជំនាន់ក្រោយ ដោយភាពស្មោះត្រង់ និងហ៊ានលះបង់ដើម្បីជំនាញ។
- មានសីលធម៌រស់នៅថ្លៃថ្នូរ។

មត៌កមនុស្សរស់ មានក្រមសីលធម៌របស់ខ្លួន ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ។

**មាត្រា ៧.-**

មត៌កមនុស្សរស់មានគោរមងារថ្នាក់ជាតិ ដែលទទួលស្គាល់ដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី។ មត៌កមនុស្សរស់មានគ្រឿងសម្គាល់របស់ខ្លួន។

## ជំពូកទី៣

## គណៈកម្មាធិការមត៌កមនុស្សរស់

**មាត្រា ៨.-**

គណៈកម្មាធិការមត៌កមនុស្សរស់ មានសមាសភាពដូចតទៅ ៖

| | |
|---|---|
| - រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | ប្រធាន |
| - តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| - តំណាង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | អនុប្រធាន |
| - តំណាង ក្រសួងអប់រំ យុវជន និង កីឡា | សមាជិក |
| - តំណាង ក្រសួងព័ត៌មាន | សមាជិក |
| - តំណាង ក្រសួងធម្មការ និង សាសនា | សមាជិក |

- តំណាង ក្រសួងសុខាភិបាល — សមាជិក
- តំណាង រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ — សមាជិក
- តំណាង រាជបណ្ឌិតសភាកម្ពុជា — សមាជិក
- សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ — សមាជិក
- តំណាង គណៈកម្មការជាតិយូណេស្កូកម្ពុជា — សមាជិក
- តំណាង គណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក — សមាជិក
- តំណាង គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា — សមាជិក
- អគ្គនាយកបច្ចេកទេសវប្បធម៌ នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ — លេខាធិការអចិន្ត្រៃយ៍
- មន្ត្រីជំនាញជាន់ខ្ពស់មួយចំនួននៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ — សមាជិក

អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មាធិការមត៌កមនុស្សរស់។

សមាសភាពជាក់ស្តែងរបស់គណៈកម្មាធិការមត៌កមនុស្សរស់ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ។

**មាត្រា ៩.-**

គណៈកម្មាធិការមត៌កមនុស្សរស់មានភារកិច្ច ដូចតទៅ ៖

- ពិនិត្យ និង សម្រេច ទម្រង់សិល្បៈវប្បធម៌អរូបីណាមួយ ដែលកំពុងរងគ្រោះឈានទៅរកការបាត់បង់
- ស្រាវជ្រាវ ពិនិត្យ ជ្រើសរើស និង វាយតម្លៃបេក្ខភាពមត៌កមនុស្សរស់ ដែលមានលក្ខណៈសម្បត្តិស្របតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា៥ និងមាត្រា៦ នៃព្រះរាជក្រឹត្យនេះ
- ស្រាវជ្រាវរកមត៌កមនុស្សរស់តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និង តាមរយៈមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈរាជធានី-ខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំយន្តការផ្ទេរចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេសដល់អ្នកជំនាន់ក្រោយ
- ចាត់ចែង ប្រើប្រាស់មធ្យោបាយសំភារៈ ថវិកា និង គ្រឿងសម្គាល់ផ្សេងៗសម្រាប់មត៌កមនុស្សរស់
- ជានាតម្កល់ទុករាល់ឯកសារអប់រំ និង ផ្សព្វផ្សាយ ស្នាដៃរបស់មត៌កមនុស្សរស់ ដើម្បីជាគុណ

ប្រយោជន៍ចំពោះសង្គមជាតិ។

- លើកទឹកចិត្តឱ្យមានការដាក់ពាក្យស្នើសុំជាបេក្ខជនមត៌កមនុស្សរស់ ពីបុគ្គល ឬ ក្រុមមនុស្សទាំងឡាយដែលយល់ថាខ្លួនមានចំណេះដឹង ជំនាញ ទេពកោសល្យ និង បច្ចេកទេសវប្បធម៌ខ្ពស់។
- ស្រាវជ្រាវ ពិនិត្យ និងវាយតម្លៃលើការស្នើសុំលាលែង និងការដកហូតតំណែងមត៌កមនុស្សរស់ពីបុគ្គល ឬ ក្រុមមនុស្សដែលបានទទួលការតែងតាំងហើយ។

## ជំពូកទី៤

## ភារកិច្ចមត៌កមនុស្សរស់

**មាត្រា ១០.-**

មត៌កមនុស្សរស់មានកាតព្វកិច្ចសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដូចខាងក្រោម ៖

- រៀបចំចងក្រងឯកសារសំរាប់បង្ហាត់បង្រៀន ផ្សព្វផ្សាយ ដែលបម្រើឱ្យប្រយោជន៍សង្គមជាតិ
- ផ្ទេរចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេសរបស់ខ្លួនដោយគ្មានលាក់លៀមដល់អ្នកជំនាន់ក្រោយតាមរយៈការបណ្តុះបណ្តាល
- ផ្សព្វផ្សាយចំណេះដឹង ជំនាញ ទេពកោសល្យ និង បច្ចេកទេស ដែលខ្លួនមានឱ្យបានទូលំទូលាយដល់សាធារណជនទូទៅតាមគ្រប់មធ្យោបាយ
- បន្តថែរក្សាឱ្យគង់វង្ស និងអភិវឌ្ឍចំណេះដឹង ជំនាញ ទេពកោសល្យ និង បច្ចេកទេស ដែលសាមីខ្លួនបានទទួលកិត្តិយស
- ទទួលភារកិច្ចផ្សេងៗទៀតដែលគណៈកម្មាធិការជំនាញមត៌កមនុស្សរស់ និង រាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា ១១.-**

បុគ្គល ឬ ក្រុមមនុស្សដែលត្រូវបានទទួលស្គាល់ជាមត៌កមនុស្សរស់ អាចរងការបដិសេធចោលនូវគោរមងារ និង ផលប្រយោជន៍ទាំងអស់នេះវិញ ដោយមូលហេតុ ៖

- អនុវត្តពុំបានទៅតាមកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា១០ នៃព្រះរាជក្រឹត្យនេះ
- ប្រព្រឹត្តផ្ទុយពីសីលធម៌ក្នុងវិជ្ជាជីវៈ ឬ ត្រូវបានតុលាការផ្តន្ទាទោសពីបទមជ្ឈិម ឬ បទឧក្រិដ្ឋណាមួយ។

ប្រសិនបើមត៌កមនុស្សរស់ទទួលមរណភាពក្នុងកេរ្តិ៍ឈ្មោះល្អ គោរមងារត្រូវបានរក្សា តែប្រាក់

ឧបត្ថម្ភជីវភាពប្រចាំខែពីថវិកាជាតិត្រូវបញ្ចប់។

**មាត្រា ១២.-**

ស្នាដៃបេតិកភណ្ឌវប្បធម៌អរូបីរបស់មត៌កមនុស្សរស់ គឺជាកម្មសិទ្ធិរបស់មត៌កមនុស្សរស់ ដែលត្រូវបានការពារដោយច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល។

## ជំពូកទី៥

## ប្រភពធនធាន និង លាភការ

**មាត្រា ១៣.-**

ប្រភពធនធានផ្គត់ផ្គង់ដល់មត៌កមនុស្សរស់ និង គណៈកម្មាធិការមត៌កមនុស្សរស់ បានមកពីថវិកាជាតិជាកញ្ចប់ថវិកាដោយឡែក ក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ។

គណៈកម្មាធិការមត៌កមនុស្សរស់ មានសិទ្ធិទទួល និង គ្រប់គ្រងមូលនិធិ ដែលបានមកពីប្រភពហិរញ្ញប្បទាន សហប្រតិបត្តិការបរទេស និង ពីប្រភពផ្សេងទៀត សម្រាប់បំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធិភាព។

**មាត្រា ១៤.-**

មត៌កមនុស្សរស់ត្រូវទទួលបានផលប្រយោជន៍ និងលាភការដូចខាងក្រោម ៖

- ប្រាក់ឧបត្ថម្ភជីវភាពប្រចាំខែពីថវិកាជាតិ។ បើមន្ត្រីរាជការទទួលការតែងតាំងជាមត៌កមនុស្សរស់ ត្រូវទទួលបានប្រាក់បំណាច់ណាមួយដែលមានចំនួនច្រើនជាង។
- ការឧបត្ថម្ភសម្ភារៈ ថវិកា និង មធ្យោបាយសម្រាប់បម្រើការសិក្សាស្រាវជ្រាវ ការបណ្តុះបណ្តាល

ផលប្រយោជន៍ និង លាភការរបស់មត៌កមនុស្សរស់ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា ១៥.-**

រាល់បទប្បញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ១៦.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវ

ទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

**៣រល.១០០២.១៦៥**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**លេខ ៖ ១៥៣ ច.ល**

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី.....ខែ កុម្ភៈ ឆ្នាំ០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**យុន ជិនគេន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ២៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំ និង ការប្រព្រឹត្តទៅរបស់
# ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

❖❖❖❖❖❖❖

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តិពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៧

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

មាត្រា១.-

អនុក្រឹត្យនេះមានគោលដៅរៀបចំបណ្តាអង្គភាពនៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ និង កំណត់បេសកកម្មរបស់ក្រសួង និង មុខងារនៃអគ្គនាយកដ្ឋាន នាយកដ្ឋាន និង អង្គភាពនានា ក្រោមឱវាទ។

## ជំពូកទី២

## បេសកកម្ម និង រចនាសម្ព័ន្ធ

មាត្រា ២.-

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្មឱ្យដឹកនាំ និង គ្រប់គ្រងវិស័យវប្បធម៌ និង វិចិត្រសិល្បៈ នៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៣.-

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ មានមុខងារ និងភារកិច្ចដូចតទៅ៖

- ប្រតិបត្តិនូវនយោបាយការពារ ថែរក្សា និង លើកតម្លៃបេតិកភណ្ឌវប្បធម៌ជាតិ និង សម្បត្តិវប្បធម៌ទូទៅនៃព្រះរាជាណាចក្រកម្ពុជា គ្រប់គ្រងរមណីយដ្ឋានវប្បធម៌ បុរាណវិទ្យា នរវិទ្យា និង ប្រវត្តិវិទ្យា
- ផ្តុំឡើងវិញ និង លើកតម្កើងបណ្តាតម្លៃវប្បធម៌ និងជំនឿទំនៀមទម្លាប់ ប្រពៃណីរបស់សង្គមជាតិ បំផុសការបង្កើតស្នាដៃ ផ្សព្វផ្សាយ និង អភិវឌ្ឍន៍សកម្មភាពវប្បធម៌
- ជាអាណាព្យាបាលបច្ចេកទេសលើសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក្នុងការបណ្តុះបណ្តាល សិល្បករ តន្ត្រីករ ស្ថាបត្យករ បុរាណវិទូ និងអ្នកជំនាញផ្សេងៗទៀតដែលពាក់ព័ន្ធនឹងវិស័យវប្បធម៌ ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៤.-

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានរចនាសម្ព័ន្ធដូចតទៅ៖

**ក. ថ្នាក់កណ្តាល៖**

-ខុទ្ទកាល័យ រដ្ឋមន្ត្រី

-អធិការដ្ឋាន

-នាយកដ្ឋានសវនកម្មផ្ទៃក្នុង

-អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

-អគ្គនាយកដ្ឋាន បច្ចេកទេសវប្បធម៌

-អគ្គនាយកដ្ឋាន បេតិកភណ្ឌ

-សាលាមធ្យមវិចិត្រសិល្បៈ

**ខ. អង្គភាពមូលដ្ឋានៈ**

-មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង

-ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈ ស្រុក-ខណ្ឌ

**គ. គ្រឹះស្ថានសាធារណៈ៖**

-សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។

-អង្គការលេខរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី៣

## ខុទ្ទកាល័យរដ្ឋមន្ត្រី

មាត្រា ៥.-

ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលមន្ទុកបេសកកម្មទាំងឡាយដែលកំណត់តាមបទប្បញ្ញត្តិ នៃអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន។

## ជំពូកទី៤

## អធិការដ្ឋាន

មាត្រា ៦.-

អធិការដ្ឋានរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ មានភារកិច្ចដូចតទៅ៖

- ធ្វើអធិការកិច្ចជាប្រចាំ ទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចហើយនោះ និងពីមធ្យោបាយកែលម្អការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ
- ប្រតិបត្តិភារកិច្ច តាមកាលដែលរដ្ឋមន្ត្រីបានប្រគល់ជូន។

អធិការដ្ឋានដឹកនាំដោយអធិការមួយរូប អមដោយអធិការរងមួយ ឬច្រើនរូបជាជំនួយការ តាមការចាំបាច់។

## ជំពូកទី៥
## នាយកដ្ឋាន សវនកម្មផ្ទៃក្នុង

**មាត្រា ៧.-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តមុខងារ និងភារកិច្ចតាមខ្លឹមសារអនុក្រឹត្យលេខ ៤០អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ។

## ជំពូកទី៦
## អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

**មាត្រា ៨.-**

អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ មានមុខងារដូចតទៅ៖

- គ្រប់គ្រងការងាររួមមាន៖ រដ្ឋបាល បូកសរុប របាយការណ៍ ឯកសារ បុគ្គលិក ផែនការស្តីពីហិរញ្ញវត្ថុ សម្ភារៈបរិក្ខារ ការងារបណ្តុះបណ្តាលក្របខ័ណ្ឌក្រសួង ការងារសហប្រតិបត្តិការវប្បធម៌អន្តរជាតិ និង កិច្ចការអាស៊ាន ការងារសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល និង នីតិកម្ម។
- សម្របសម្រួលរាល់សកម្មភាពរដ្ឋបាលនៅក្នុងក្រសួង ជាមួយបណ្តាអង្គភាពមូលដ្ឋានខេត្ត-ក្រុង និង ជាមួយបណ្តាក្រសួងនានា។

**មាត្រា ៩.-**

អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ត្រូវបានដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួន ជាជំនួយការតាមការចាំបាច់។

អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ មាននាយកដ្ឋានចំណុះចំនួន៨(ប្រាំបី) និង សាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌ថ្នាក់ស្មើនាយកដ្ឋាន៖

-នាយកដ្ឋាន រដ្ឋបាលទូទៅ

-នាយកដ្ឋាន បុគ្គលិក

-នាយកដ្ឋាន នីតិកម្ម

-នាយកដ្ឋាន គណនេយ្យ និង ហិរញ្ញវត្ថុ

-នាយកដ្ឋាន សម្ភារៈ និង បរិក្ខារ

-នាយកដ្ឋាន ផែនការ ស្ថិតិ និង សរុប

-នាយកដ្ឋាន សិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល

-នាយកដ្ឋាន សហប្រតិបត្តិការវប្បធម៌ អន្តរជាតិ និង កិច្ចការអាស៊ាន

-សាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌។

**មាត្រា ១០.-**

នាយកដ្ឋានរដ្ឋបាលទូទៅ មានភារកិច្ចដូចតទៅ៖

- សម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និង រវាងថ្នាក់កណ្តាល និង អង្គភាពមូលដ្ឋានក្រោមឱវាទ
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង
- ធានាប្រសិទ្ធិភាព សុវត្ថិភាពរដ្ឋបាល
- រក្សា និងតម្កល់ឯកសាររបស់ក្រសួង
- គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានរដ្ឋបាលទូទៅ ដឹកនាំដោយប្រធានមួយរូប និង អនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ១១.-**

នាយកដ្ឋានបុគ្គលិក មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងផ្នែករដ្ឋបាលមន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយធ្វើទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- រៀបចំរាល់លិខិតរដ្ឋបាលសម្រាប់ការគ្រប់គ្រងអាជីព
- ធ្វើកម្មវិធីពីតំណែង ឯកទេស និង ធនធានមនុស្សរបស់ក្រសួង
- វាយតម្លៃតម្រូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក និង ពិនិត្យបញ្ជូនមន្ត្រីជំនាញទៅធ្វើសុក្រឹតការ ឬបន្តការសិក្សានៅក្នុង និងក្រៅប្រទេស
- រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និងបន្ត ដោយធ្វើទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈដើម្បីអនុវត្តនយោបាយនោះ

- រៀបចំការប្រឡងជ្រើសរើសបញ្ចូលក្របខ័ណ្ឌក្រសួងឱ្យសមស្របតាមនយោបាយរបស់ក្រសួង
- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងព័ត៌មានប្រតិបត្តិ
- គ្រប់គ្រងការងារសង្គមរបស់ក្រសួង
- សហការជាមួយបណ្ដាអង្គភាព និងគ្រឹះស្ថានសិក្សាបច្ចេកទេសវប្បធម៌ ដើម្បីចូលរួមកសាងកម្មវិធីសិក្សា និង សកម្មភាពរបស់អង្គភាពទាំងនោះ សម្រាប់ការបណ្ដុះបណ្ដាលឱ្យស្របទៅតាមតម្រូវការអភិវឌ្ឍនៃសង្គមជាតិ
- លើកសំណើបង្កើត ឬរំសាយអង្គភាពនានា រៀបចំតួនាទីភារកិច្ច កែសម្រួលរចនាសម្ព័ន្ធតាមស្ថានភាពជាក់ស្ដែង
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានបុគ្គលិក ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ១២.-**

នាយកដ្ឋាននីតិកម្ម មានភារកិច្ចដូចតទៅ៖

- សិក្សាស្រាវជ្រាវ ឯកសារច្បាប់ជាតិ អន្តរជាតិ និងលិខិតបទដ្ឋាននានា ពាក់ព័ន្ធលើការគ្រប់គ្រងវិស័យវប្បធម៌ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួង
- រៀបចំ កសាងផែនការច្បាប់ និងលិខិតបទដ្ឋាននានារបស់ក្រសួង
- រៀបចំ តាក់តែងសេចក្ដីព្រាងច្បាប់ និង លិខិតបទដ្ឋាននានា លើវិស័យវប្បធម៌ ដោយធ្វើការទំនាក់ទំនងជាមួយអង្គភាពជំនាញ និង ស្ថាប័នអ្នកច្បាប់
- ចងក្រង និងតម្កល់ទុករាល់ឯកសារច្បាប់ទាំងឡាយពាក់ព័ន្ធលើវិស័យវប្បធម៌
- ផ្សព្វផ្សាយ និង តាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានារបស់វិស័យវប្បធម៌ដល់បណ្ដាអង្គភាព នាយកដ្ឋាន និង គ្រឹះស្ថានដែលពាក់ព័ន្ធ
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋាននីតិកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

មាត្រា ១៣.-

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ៖

- ប្រមូលចំណូលឱ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុដែលបានកំណត់
- លើកគម្រោងថវិការក្រសួង និងតាមដានរំលឹកពីការប្រតិបត្តិ
- ប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកា
- តាមដាន រំលឹក ការគ្រប់គ្រងរាល់ចំណាយរបស់ក្រសួង
- គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តលទ្ធកម្មសាធារណៈ
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

មាត្រា ១៤.-

នាយកដ្ឋានសម្ភារៈ និង បរិក្ខារ មានភារកិច្ចដូចតទៅ៖

- ប្រមូលផ្តុំតម្រូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំជួសជុលសម្ភារៈ និង បរិក្ខាររបស់ក្រសួង
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភណ្ឌ
- គ្រប់គ្រងយានដ្ឋាន និង យានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួង ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់
- ទទួល និង បែងចែកបរិក្ខារជូនដល់បណ្តាអង្គភាព ខេត្ត-ក្រុងនានា
- កាន់បញ្ជីជាប្រចាំនូវសលាកប័ត្រ និងគណនេយ្យរូបធាតុ
- ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិលទ្ធកម្មសាធារណៈ
- ព័ត៌មានវិទ្យាសកម្មភាពការងាររបស់ខ្លួន
- ធ្វើរបាយការណ៍ពីសកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានសម្ភារៈ និង បរិក្ខារ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយ

ការ តាមការចាំបាច់។

**មាត្រា ១៥.-**

នាយកដ្ឋានផែនការ ស្ថិតិ និង សរុប មានភារកិច្ចដូចតទៅៈ

- ធ្វើឱ្យសម្រេច និង ផ្សព្វផ្សាយនូវការងារសិក្សាស្រាវជ្រាវ និង បូកសរុប ដែលពាក់ព័ន្ធនឹងវិទ្យាសាស្ត្រសង្គម និង សេដ្ឋកិច្ចនៃវិស័យវប្បធម៌ ព្រមទាំងផ្ទៀងផ្ទាត់ការប្រើប្រាស់បានល្អនូវបណ្ដាលទ្ធផលទាំងនោះ។
- វិភាគ និង កសាងផែនការអភិវឌ្ឍន៍វិស័យវប្បធម៌ រយៈពេលខ្លី មធ្យម និងវែង នឹងតាមដានការអនុវត្តនោះ
- រៀបចំ កសាងគោលនយោបាយយុទ្ធសាស្ត្រ និងកម្មវិធីអភិវឌ្ឍន៍វិស័យវប្បធម៌ និងកំណត់គោលដៅនៃការអភិវឌ្ឍនោះ
- សិក្សាពិចារណាលើវិធីសាស្ត្រធ្វើការងារក្នុងក្រសួង ព្រមទាំងលើកសំណើផ្សេងៗដើម្បីកែសម្រួល
- រៀបចំ កសាងកម្មវិធីវិនិយោគសាធារណៈ និង រៀបចំតម្រង់ទិសកម្មវិធីវិនិយោគឯកជនក្នុងវិស័យវប្បធម៌
- រៀបចំ គម្រោងផែនការអំពីតម្រូវការចាំបាច់នានារបស់ក្រសួង ដើម្បីបញ្ចូលទៅក្នុងថវិការដ្ឋ និងសុំជំនួយឧបត្ថម្ភផ្សេងៗ
- សហការជាមួយក្រសួងផែនការ ដើម្បីរៀបចំប្រព័ន្ធស្ថិតិមួយ អំពីជីវភាពវប្បធម៌ទូទាំងប្រទេស
- រៀបចំចងក្រងកម្មវិធីវប្បធម៌ សម្រាប់ផ្សព្វផ្សាយតាមរយៈកម្មវិធីវិទ្យុ និងទូរទស្សន៍
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានផែនការ ស្ថិតិ និងសរុប ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ១៦.-**

នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល មានភារកិច្ចដូចតទៅៈ

- លើកកម្មវិធីនយោបាយ ស្ដីពីវិស័យសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល
- អនុវត្តទូលំទូលាយនយោបាយសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល ក្នុងគោលដៅជំរុញ

លើកទឹកចិត្តក្នុង ការបង្កបង្កើតផលិតផលថ្មី ខាងវិស័យវប្បធម៌

- គ្រប់គ្រងសម្របសម្រួល និង ធ្វើឱ្យប្រសើរឡើងនូវការអនុវត្តច្បាប់សិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល
- ជំរុញការបង្កើត ការណែនាំ និង ការត្រួតពិនិត្យអង្គភាពគ្រប់គ្រងសិទ្ធិរួម
- អប់រំ និង ផ្សព្វផ្សាយឱ្យមានការយល់ដឹងអំពីកម្មសិទ្ធិបញ្ញាផ្នែកសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល ដឹកនាំដោយប្រធានមួយរូប និង អនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ១៧.-**

នាយកដ្ឋានសហប្រតិបត្តិការវប្បធម៌ និងកិច្ចការអាស៊ាន មានភារកិច្ចដូចតទៅ៖

- កសាង និង គ្រប់គ្រងរាល់ឯកសារការងារសហប្រតិបត្តិការវប្បធម៌ជាមួយបណ្តាប្រទេសលើសកលលោក
- គ្រប់គ្រងខ្លឹមសារនៃកិច្ចព្រមព្រៀងលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈ ជាមួយអន្តរជាតិ អាស៊ាន ដោយធ្វើការតាមដាន និង ជំរុញការអនុវត្តឱ្យមានប្រសិទ្ធិភាព
- វាយតម្លៃ និង រៀបចំកិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការ ជាមួយបណ្តាប្រទេសលើសកលលោក ពិសេសប្រទេសអាស៊ាន អំពីវិស័យវប្បធម៌
- សហការ និងសម្របសម្រួលជាមួយបណ្តាក្រសួង អង្គទូត អង្គការជាតិ និងអន្តរជាតិ សមាគមនានា ដើម្បីរៀបចំខ្លឹមសារកិច្ចព្រមព្រៀង និង គម្រោងស្នើសុំជំនួយដែលពាក់ព័ន្ធនឹងវិស័យវប្បធម៌
- រៀបចំសម្រួលបែបបទជូនគណៈប្រតិភូ កម្មសិក្សាការីរបស់ក្រសួង ដែលចេញទៅបំពេញទស្សនកិច្ច ឬ កម្មសិក្សា និងសកម្មភាពផ្លាស់ប្តូរវប្បធម៌ជាមួយអន្តរជាតិ តាមការសម្រេចរបស់ប្រធានស្ថាប័ន។
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានសហប្រតិបត្តិការវប្បធម៌អន្តរជាតិ និងកិច្ចការអាស៊ាន ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ១៨.-**

សាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌ មានភារកិច្ចដូចតទៅ៖

- ធ្វើការបណ្តុះបណ្តាលនូវមុខវិជ្ជាជំនាញចាំបាច់ មុនបញ្ចូលជាក្របខ័ណ្ឌមន្ត្រីរាជការរបស់ក្រសួង
- រៀបចំធ្វើវិក្រឹតការ និងសុក្រឹតការមន្ត្រីរាជការរបស់ក្រសួង
- រៀបរៀងកម្មវិធីសិក្សាសមស្របតាមការរៀបចំក្របខ័ណ្ឌមន្ត្រីរាជការរបស់ក្រសួង
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

សាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌ ដឹកនាំដោយនាយកមួយរូប និងនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់។

## ជំពូកទី៧
## អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌

**មាត្រា ១៩.-**

អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ មានមុខងារអនុវត្តនូវរាល់បេសកកម្មរបស់ក្រសួង ក្នុងការប្រតិបត្តិនយោបាយលើវិស័យអភិវឌ្ឍន៍វប្បធម៌ និងអប់រំសិល្បៈ ភាពយន្ត វីដេអូ និងពហុមេឌីយ៉ា សិល្បៈទស្សនីយភាព សិល្បៈ សូនរូប និងសិល្បៈសិប្បកម្ម សៀវភៅ និងការអានសាធារណៈ។

**មាត្រា ២០.-**

អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ ត្រូវបានដឹកនាំដោយអគ្គនាយកមួយរូប អមដោយអគ្គនាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់។

អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ មាននាយកដ្ឋានចំណុះចំនួន ៥ (ប្រាំ)៖

-នាយកដ្ឋាន អភិវឌ្ឍន៍វប្បធម៌

-នាយកដ្ឋាន សិល្បៈភាពយន្ត និង ផ្សព្វផ្សាយវប្បធម៌

-នាយកដ្ឋាន សិល្បៈទស្សនីយភាព

-នាយកដ្ឋាន សិល្បៈសូនរូប និង សិល្បៈសិប្បកម្ម

-នាយកដ្ឋាន សៀវភៅ និង ការអាន។

**មាត្រា ២១.-**

នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ មានភារកិច្ចដូចតទៅ៖

- លើកទឹកចិត្តរាល់សកម្មភាពវប្បធម៌ ព្រមទាំងរៀបចំចាត់តាមងបណ្ដាការសម្ដែងសិល្បៈវប្បធម៌ ពិពណ៌ សំដៅធ្វើឱ្យមហាជនចាប់អារម្មណ៍ និង វប្បធម៌របស់ខ្លួន
- បំផុសនិងសម្រួលដល់សមាគមវិជ្ជាជីវៈផ្សេងៗក្នុងវិស័យវប្បធម៌ សំដៅលើកកម្ពស់មនសិការវិជ្ជាជីវៈ ព្រមទាំងការពារផលប្រយោជន៍ស្របច្បាប់របស់គេ
- លើកទឹកចិត្ត និង ត្រួតពិនិត្យចំពោះការថែរក្សារាល់សកម្មភាពវប្បធម៌ល្អៗរបស់ប្រជាពលរដ្ឋតាមតំបន់ទូទាំងប្រទេស
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ២២.-**

នាយកដ្ឋានសិល្បៈភាពយន្ត និង ផ្សព្វផ្សាយវប្បធម៌ មានភារកិច្ចដូចតទៅ៖

- តម្រង់ទិស និង លើកទឹកចិត្តក្នុងការផ្សព្វផ្សាយវប្បធម៌ និង សិល្បៈ តាមរយៈភាពយន្ត វីដេអូ និងពហុមេឌីយ៉ា
- សិក្សា និងអនុញ្ញាត ការធ្វើអាជីវកម្មសិល្បៈទី៧ ក្នុងរូបភាពជាភាពយន្ត និង វីដេអូ
- រក្សាឯកសារភាពយន្ត និង វីដេអូជាតិ
- អនុញ្ញាត និង លើកទឹកចិត្តធ្វើឱ្យអភិវឌ្ឍសិល្បៈទី៧ ក្នុងរូបភាពជាភាពយន្ត និងវីដេអូ
- ផលិត ផ្សព្វផ្សាយ គ្រប់គ្រង និង ត្រួតពិនិត្យវិស័យវប្បធម៌តាមរូបភាព ភាពយន្ត វីដេអូ និង ពហុមេឌីយ៉ា ដោយសហការជាមួយក្រសួងពាក់ព័ន្ធ
- បណ្ដុះបណ្ដាល បំពាក់បំប៉ន មុនជំនាញភាពយន្ត និង វីដេអូ
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធាន

មួយចំនួន ជាជំនួយការ តាមការចាំបាច់។

**មាត្រា ២៣.-**

នាយកដ្ឋានសិល្បៈទស្សនីយភាព មានភារកិច្ចដូចតទៅ៖

- លើកទឹកចិត្តការបង្កើតស្នាដៃធ្វើឱ្យសម្បូរបែប ព្រមទាំងផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវទស្សនីយភាពរស់ មានវិស័យ ល្ខោន អាយ៉ៃ ចាប៉ីដងវែង យីកេ តន្ត្រី របាំ សៀក និងទស្សនីយភាពប្រជាប្រិយប្លែកៗផ្សេងទៀត
- កំណត់នូវនយោបាយវិមជ្ឈការ អំពីជំនាញសិល្បៈចំពោះបណ្ដាក្រុមសិល្បៈតាមខេត្ត-ក្រុងទូទាំងប្រទេស
- សហការជាមួយសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក្នុងការបណ្ដុះបណ្ដាលសិល្បករ នៃវិស័យសិល្បៈរស់
- លើកឡើងនូវនយោបាយ អំពីការពិចារណា និងការកែសម្រួលបណ្ដាវិជ្ជាជីវៈនិងការរៀបចំវិស័យសិល្បៈ
- សិក្សាអំពីសកម្មភាពទាំងឡាយ សំដៅពង្រីកទស្សនិកជន
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានសិល្បៈទស្សនីយភាព ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់។

**មាត្រា ២៤.-**

នាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម មានភារកិច្ចដូចតទៅ៖

- ណែនាំ និង គ្រប់គ្រង លើគោលការណ៍ជំនាញ ដើម្បីពង្រឹងគុណភាពដល់បណ្ដាសមាគមអ្នកបង្កើតស្នាដៃ អាជីវកម្ម សេវាកម្ម សិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ស្របតាមបេសកកម្មរបស់ក្រសួង
- ចងក្រងឯកសារសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ដើម្បីទុកជាក្បួនខ្នាតសម្រាប់កំណត់បទដ្ឋានបច្ចេកទេស
- បង្កើតកម្មវិធីបណ្ដុះបណ្ដាល និង ផ្សព្វផ្សាយវិជ្ជាជីវៈសិល្បៈសូនរូប និង សិល្បៈសិប្បកម្ម ជូនដល់មហាជន ដែលមានវិជ្ជាជីវៈសិល្បៈសូនរូប និង សិល្បៈសិប្បកម្ម

- តម្រង់ទិសបំផុសការបង្កើតស្នាដៃ និងលើកទឹកចិត្តដល់អ្នកបង្កើតស្នាដៃ ព្រមទាំងផ្សព្វផ្សាយក្នុងចំណោមមហាជន នូវរាល់រូបភាពសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ២៥.-**

នាយកដ្ឋានសៀវភៅ និង ការអាន មានភារកិច្ចដូចតទៅ៖

- ថែរក្សា ការពារ និងលើកតម្កើងរាល់ស្នាដៃសរសេរ ដែលបានរក្សាទុក និងតម្កល់ទុកតាមច្បាប់
- ទ្រទ្រង់ចំពោះសៀវភៅគ្រប់ប្រភេទ បង្កលក្ខណៈងាយស្រួលក្នុងការបង្កើតចេញជាសៀវភៅ និងជួយគាំពារចំពោះការផ្សព្វផ្សាយ
- ធ្វើឱ្យសៀវភៅទៅដល់មនុស្សគ្រប់រូប តាមរយៈការអានជាសាធារណៈ
- គ្រប់គ្រងបណ្ណាល័យជាតិ និងបណ្ណាល័យនៅតាមខេត្ត-ក្រុង
- អនុញ្ញាតឱ្យបើក និងត្រួតពិនិត្យបណ្ណាគារគ្រប់ប្រភេទ
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានសៀវភៅ និងការអាន ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

## ជំពូកទី៨
## អគ្គនាយកដ្ឋានបេតិកភណ្ឌ

**មាត្រា ២៦.-**

អគ្គនាយកដ្ឋានបេតិកភណ្ឌ មានមុខងារអនុវត្តរាល់បេសកកម្មរបស់ក្រសួង ក្នុងប្រតិបត្តិការនយោបាយលើផ្នែកបេតិកភណ្ឌ សារមន្ទីរ គាំពារ និងអភិរក្សសំណង់បុរាណ និងវត្ថុបុរាណ ការស្រាវជ្រាវ រុករក និងកំណាយស្ថានីយ៍បុរេប្រវត្តិ ប្រវត្តិសាស្ត្រដែលកប់ក្នុងដី ក្រោមទឹក និងការអប់រំផ្សព្វផ្សាយ។

**មាត្រា ២៧.-**

អគ្គនាយកដ្ឋានបេតិកភណ្ឌ ត្រូវបានដឹកនាំដោយអគ្គនាយកមួយរូប អមដោយអគ្គនាយករង មួយចំនួនជា ជំនួយការ តាមការចាំបាច់។

អគ្គនាយកដ្ឋានបេតិកភណ្ឌ មាននាយកដ្ឋានចំណុះចំនួន ៤ (បួន) ៖

-នាយកដ្ឋាន បុរាណវត្ថុ

-នាយកដ្ឋាន សារមន្ទីរ

-នាយកដ្ឋាន គាំពារ និងអភិរក្សសំណង់បុរាណ

-នាយកដ្ឋាន បុរាណវិទ្យា បុរេប្រវត្តិវិទ្យា។

**មាត្រា ២៨.-**

នាយកដ្ឋាន បុរាណវត្ថុ មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រង និងអភិរក្សរាល់បុរាណវត្ថុផ្សេងៗដែលមានតម្លៃជាប្រវត្តិសាស្ត្រ សិល្បៈ សាសនា ឬ វិទ្យាសាស្ត្រ ហើយដែលកិច្ចការពាររាល់ចលនសម្បត្តិវប្បធម៌ទាំងឡាយនោះបម្រើឱ្យប្រយោជន៍ សាធារណៈ
- រៀបចំចងក្រងលិខិតបទដ្ឋានផ្សេងៗ ដើម្បីធានាដល់ការពារបុរាណវត្ថុ និងត្រួតពិនិត្យលើការ នាំចេញ-នាំចូល វត្ថុសិល្បៈផ្សេងៗ ដើម្បីទប់ស្កាត់ចរាចរសម្បត្តិវប្បធម៌ខុសច្បាប់
- រៀបចំ និង ផ្តល់អាជ្ញាប័ណ្ណ សម្រាប់ការសុំអនុញ្ញាតនាំចេញ នាំចូល វត្ថុសិល្បៈផ្សេងៗ
- ចុះអប់រំ និងផ្សព្វផ្សាយ ដល់សាធារណជន អំពីច្បាប់ការពារបេតិកភណ្ឌវប្បធម៌ និងលិខិត បទដ្ឋានផ្សេងៗ ដែលមានទិសដៅថែរក្សា និងការពារឱ្យបានគង់វង្សនូវសម្បត្តិវប្បធម៌ជាតិ
- ទទួលអនុវត្តសិទ្ធិស្នើសុំ ឬប្តឹងទាមទារឱ្យធ្វើការបញ្ជូនត្រឡប់មកប្រទេសកម្ពុជាវិញ នូវបុរាណ វត្ថុ ទាំងឡាយណាដែលត្រូវបានគេនាំចេញ ឬធ្វើនីហរណកម្មដោយខុសច្បាប់
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានបុរាណវត្ថុ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាម ការចាំបាច់។

**មាត្រា ២៩.-**

នាយកដ្ឋានសារមន្ទីរ មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងការអភិរក្ស ការថែរក្សា ការជួសជុល ការសិក្សា និងការធ្វើឱ្យសំបូរបែបនៃសមុច្ច័យសាធារណៈ
- ជានាការផ្សព្វផ្សាយ និង ការតាំងបង្ហាញសមុច្ច័យទាំងឡាយចំពោះសាធារណជន ព្រមទាំងត្រួតពិនិត្យតាមលក្ខណៈវិទ្យាសាស្ត្របច្ចេកទេសបណ្ដាសមុច្ច័យទាំងនោះ
- គ្រប់គ្រងលើសារមន្ទីរដ្ឋ និង សារមន្ទីគ្រប់ប្រភេទនៅទូទាំងប្រទេស
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានសារមន្ទីរ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ៣០.-**

នាយកដ្ឋាន គាំពារ និងអភិរក្សសំណង់បុរាណ មានភារកិច្ចដូចតទៅៈ

- ធ្វើបញ្ជី និងធ្វើចំណាត់ថ្នាក់ប្រាសាទបុរាណ រមណីយដ្ឋានវប្បធម៌ និងសំណង់បុរាណផ្សេងៗទៀត ដែលមាននៅតាមខេត្ត-ក្រុងនានា ដោយសហការយ៉ាងជិតស្និទជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង ដើម្បីរៀបចំទុក ជាឯកសារ
- គ្រប់គ្រង និងសិក្សាស្រាវជ្រាវ ដើម្បីអនុវត្តកិច្ចការពារបេតិកភណ្ឌវប្បធម៌ ដូចមានចែងនៅក្នុងច្បាប់ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ
- រៀបចំ ស្ថាបនាអភិរក្សដ្ឋាន នៅតាមបណ្ដាប្រាសាទ និងរមណីយដ្ឋានវប្បធម៌នានា ដោយមានអភិរក្សករ និងអ្នកជំនាញផ្សេងៗធ្វើការនៅទីនោះ
- សិក្សាស្រាវជ្រាវ និងចងក្រងជាឯកសារប្រវត្តិសាស្ត្រ និងវិទ្យាសាស្ត្រ នូវបណ្ដាប្រាសាទបុរាណរមណីយដ្ឋានវប្បធម៌ និងសំណង់បុរាណ ដែលទើបរកឃើញថ្មីពុំទាន់បោះពុម្ពផ្សព្វផ្សាយ
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ៣១.-**

នាយកដ្ឋានបុរាណវិទ្យា និង បុរេប្រវត្តិវិទ្យា មានភារកិច្ចដូចតទៅៈ

- ស្រាវជ្រាវ រុករកកំណត់ទីតាំង និងចុះបញ្ជីទីតាំងនៃស្ថានីយ៍បុរេប្រវត្តិ និងប្រវត្តិសាស្ត្រ ដែលកប់ក្នុងដី និង ក្រោមទឹក
- ធ្វើកំណាយស្របច្បាប់លើស្ថានីយ៍មួយចំនួន ដែលមានសារៈសំខាន់ក្នុងការយល់ដឹងពីសង្គម និងវប្បធម៌សម័យបុរាណ
- ធ្វើការវិភាគរាល់វត្ថុបុរាណ ដែលជីកបានពីស្ថានីយ៍ដែលមានប្រភពច្បាស់លាស់
- ផ្សព្វផ្សាយនូវព័ត៌មានដែលស្រាវជ្រាវរកឃើញ ពីកំណាយស្របច្បាប់ ដើម្បីចែករំលែកចំណេះដឹងដល់មន្ត្រីក្រសួង និង បញ្ញាវន្តទូទៅ
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

## ជំពូកទី៩
## សាលាមធ្យមវិចិត្រសិល្បៈ

**មាត្រា ៣២.-**

សាលាមធ្យមវិចិត្រសិល្បៈ មានភារកិច្ចដូចតទៅ៖

- ជ្រើសរើសសិស្សតាមឧបនិស្ស័យឱ្យចូលសិក្សា និង ប្រឡងបញ្ចប់ ដោយផ្តល់នូវសញ្ញាប័ត្រសិល្បៈ និង ស្នាតកប័ត្រសិល្បៈ
- បណ្តុះបណ្តាលធនធានមនុស្សចាប់តាំងពីកម្រិតបឋម ដល់មធ្យម ដើម្បីឱ្យក្លាយជាអ្នកជំនាញសិល្បៈទាំងទ្រឹស្តី ទាំងការអនុវត្ត និង ការបង្កើតថ្មីតាមការចាំបាច់របស់សង្គម
- បំពាក់បំប៉នមន្ត្រីជំនាញ និង សិល្បករ ឱ្យក្លាយជាគ្រូបង្ហាត់ដែលមានគរុកោសល្យសិល្បៈ និងវិជ្ជាជីវៈពេញលេញ
- ស្រាវជ្រាវចងក្រងកម្មវិធីសិក្សា និង វិធីសាស្ត្របង្រៀនទុកជាឯកសារបច្ចេកទេសសិល្បៈ
- សម្របសម្រួលកម្មវិធីសិក្សាជាមួយសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និង សហការជាមួយអង្គការជាតិ និង អន្តរជាតិ លើមូលដ្ឋានការងារបណ្តុះបណ្តាល និង ស្រាវជ្រាវបច្ចេកទេសសិល្បៈ ដើម្បីធ្វើការឱ្យកាន់តែប្រសើរឡើងនូវការអប់រំសិល្បៈ
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន

- ទទួលអនុវត្តការកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

មាត្រា ៣៣.-

សាលាមធ្យមវិចិត្រសិល្បៈ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងនាយករងមួយចំនួន មានឋានៈស្មើអនុប្រធាននាយកដ្ឋានជាជំនួយការ តាមការចាំបាច់។

សាលាមធ្យមវិចិត្រសិល្បៈ អាចបង្កើតសាលាឯកទេសសិល្បៈ ទៅតាមការរីកចម្រើន និងតម្រូវការចំពោះមុខរបស់សង្គមជាតិ។

## ជំពូកទី១០

## អង្គភាពមូលដ្ឋាន

មាត្រា ៣៤.-

នៅតាម ខេត្ត-ក្រុង នីមួយៗ មានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុងមួយ ដែលទទួលបន្ទុកអនុវត្ត និង សម្របសម្រួលសកម្មភាពរបស់ក្រសួង។ នៅតាមស្រុក-ខណ្ឌ នីមួយៗ មានការិយាល័យវប្បធម៌ និង វិចិត្រសិល្បៈ។

ស្រុក-ខណ្ឌ ដែលទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពរបស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង។

## ជំពូកទី១១

## គ្រឹះស្ថានសាធារណៈ

មាត្រា ៣៥.-

អង្គភាពដែលស្ថិតនៅមាត្រា៤ ចំណុច គ នៃអនុក្រឹត្យនេះ ត្រូវបាននិងរៀបចំឱ្យទៅជាគ្រឹះស្ថានសាធារណៈ ឧបនិស្ស័យរដ្ឋបាល ក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ការរៀបចំ និង ការប្រព្រឹត្តទៅរបស់គ្រឹះស្ថានសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យដែលមានលក្ខន្តិកៈមួយដោយឡែករបស់ខ្លួន ដោយអនុវត្តស្របតាមព្រះរាជក្រឹត្យលេខ នស/រកត / ១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

## ជំពូកទី១២

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា ៣៦.-

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានបង្កើតឡើងដោយ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

តាមលក្ខខណ្ឌនៃបទបញ្ជាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាក្នុងបណ្តាក្រសួង។

## ជំពូកទី១៣

## អវសានប្បញ្ញត្តិ

**មាត្រា ៣៧.-**

បទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៧ និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៣៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័ន ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

លេខ៖ ២៦ ចល.បុ
បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ផ្ញើជូនគ្រប់នាយកដ្ឋានក្រោមឳវាទក្រសួង
និងមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្ត-ក្រុង
ភ្នំពេញ, ថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៧
ជ. រដ្ឋមន្ត្រីស្តីទី
រដ្ឋលេខាធិការ

**ឃឹម សារិទ្ធ**

**<u>កន្លែងទទួល៖</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៣៨
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

**លេខ ៖ ២១៦ សហវ.ប្រក** រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១២

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ប្រភពធនធាន និង លាភការ របស់មត៌កមនុស្សរស់

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**និង**

**រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល
- បានឃើញព្រះរាជក្រមលេខ នស/រកត/០២១០/១៦៣ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីប្រព័ន្ធមត៌កមនុស្សរស់នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨១១ អនក្រ.បក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការកំណត់សមាសភាពនៃគណៈកម្មាធិការមត៌កមនុស្សរស់
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ។

## សម្រេច

**ប្រការ ១ ៖** អនុញ្ញាតឲ្យមានកញ្ចប់ថវិកាដោយឡែកក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំ របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ សម្រាប់ផ្គត់ផ្គង់ដល់មនុស្សមត៌កមនុស្សរស់ និង សម្រាប់បំពេញការងាររបស់គណៈកម្មាធិការមត៌កមនុស្សរស់។

គណៈកម្មាធិការមត៌កមនុស្សរស់ ត្រូវរៀបចំគម្រោងចំណាយថវិកាក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ សម្រាប់ដំណើរការអនុវត្តកន្សោមយន្តការគ្រប់គ្រងមត៌កមនុស្សរស់។

**ប្រការ ២ ៖** គណៈកម្មាធិការមត៌កមនុស្សរស់ អាចទទួលបានមូលនិធិ ថវិកា សម្ភារៈ គាំទ្រនានា ពីគ្រប់ផ្នែក ទាំងរដ្ឋាភិបាល ផ្នែកឯកជន ដៃគូអភិវឌ្ឍក្នុង និង ក្រៅប្រទេស ដើម្បីបំពេញកិច្ចការរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

**ប្រការ ៣ ៖** បុគ្គល ឬ ក្រុមមនុស្សដែលបានទទួលស្គាល់ជាមត៌កមនុស្សរស់ ត្រូវទទួលបានផលប្រយោជន៍ និង លាភការដូចខាងក្រោម ៖

- ប្រាក់ឧបត្ថម្ភជីវភាពប្រចាំខែពីថវិកាជាតិ។ ប្រាក់ឧបត្ថម្ភនេះមានចំនួនស្មើនឹងប្រាក់បំណាច់មុខងារកំរិតទី៥របស់អគ្គនាយក។ បើមន្រ្តីរាជការទទួលបានការតែងតាំងជាមត៌កមនុស្សរស់ ត្រូវបានទទួលបានប្រាក់បំណាច់ណាមួយដែលច្រើនជាង។
- ឧបត្ថម្ភសំភារៈ ថវិកា និង មធ្យោបាយនានា សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវ ការបណ្តុះបណ្តាល ការផ្ទេរចំណេះដឹង និង ការបង្កើតស្នាដៃ។
- គ្រប់សកម្មភាពនៃការសិក្សាស្រាវជ្រាវ ការចងក្រងថែរក្សាក្បួនច្បាប់ និង ការបង្កើតស្នាដៃត្រូវទទួលបាននូវការជួយជ្រោមជ្រែង តាមរយៈនៃការផ្តល់កញ្ចប់ថវិកាច្បាស់លាស់លើកិច្ចការនីមួយៗដែលសម្រេចបាន។

**ប្រការ ៤ ៖** បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥ ៖** គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** | **ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ** |
| **គាត ឈន់** | **ហ៊ឹម ឆែម** |

**ចម្លងជូន ៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង/ស្ថាប័ន
-គណៈកម្មាធិការមត៌កមនុស្សរស់
-គ្រប់សាលាខេត្ត និង សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ៥ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**
លេខ ៖ ១៧២ ប្រ.ក

# ប្រកាស
# ស្ដីពី
# ការដាក់តាំង ផ្ទាំងឃោសនា ផ្ទាំងផ្សាយពាណិជ្ជកម្ម ផ្ទាំងសញ្ញា

-------

## រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម /០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យ លេខ ៦២អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញសេចក្តីជូនដំណឹងលេខ ១៣៥ សជណ.សរ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០២ ស្តីពីលទ្ធផលសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី១១ ខែមករា ឆ្នាំ២០០២ និងស្មារតីអង្គប្រជុំអន្តរក្រសួង នាទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០២

## សម្រេច

**ប្រការ ១.-**

- ផ្ទាំងយីហោ គឺគ្រឿងបង្ហាញ និង សំគាល់នាមរបស់អាជីវករ គ្រឹះស្ថាននានា ដែលធ្វើការផលិត ធ្វើសេវាកម្ម ឬ ធ្វើពាណិជ្ជកម្ម។
- ផ្ទាំងផ្សាយពាណិជ្ជកម្ម គឺជាគ្រឿងបង្ហាញ និង ផ្សព្វផ្សាយ យីហោ ឬ មុខទំនិញ សំដៅទាក់ទាញអតិថិជន ក្នុងគោលដៅធ្វើអាជីវកម្ម។
- ផ្ទាំងសញ្ញា គឺជាគ្រឿងសំគាល់ និង បង្ហាញអំពីព្រឹត្តិការណ៍ ព័ត៌មាន សកម្មភាព និមិត្តរូប ពេលវេលា ឈ្មោះ ជូនសាធារណជន សំរាប់ចំណាំ ចងចាំ និង អនុវត្ត។

**ប្រការ ២.-**

អំពីរូបភាព ការដាក់តាំងផ្សព្វផ្សាយ និង ការគ្រប់គ្រងត្រួតពិនិត្យ ផ្ទាំងយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្ម ផ្ទាំងសញ្ញា ត្រូវសរសេរឱ្យបានត្រឹមត្រូវតាមពាក្យពេចន៍ និង អក្ខរាវិរុទ្ធជា អក្សរខ្មែរ ដោយអនុវត្តតាមវចនានុក្រមរបស់សម្តេចព្រះមហាសុមេធាធិបតីជោតញ្ញាណោ ជួន ណាត បោះពុម្ព នាឆ្នាំ១៩៦៧-១៩៦៨ ជាមូលដ្ឋាន។

អក្សរខ្មែរត្រូវសរសេរឲ្យបានធំជាងអក្សរបរទេស ហើយដាក់នៅជួរខាងលើគេបំផុត។

**ប្រការ ៣.-**

អក្សរបរទេសអាចសរសេរនៅពីខាងក្រោមហើយមានទំហំពាក់កណ្តាលនៃអក្សរខ្មែរ។ អក្សរបរទេសត្រូវសរសេរឲ្យបានត្រឹមត្រូវតាមពាក្យពេចន៍ អក្ខរាវិរុទ្ធជាអក្សរបរទេសនិមួយៗ ដើម្បីលើកតម្កើងកិត្យានុភាពជាតិ។

**ប្រការ ៤.-**

ម្ចាស់ដាក់តាំង និង ផ្សព្វផ្សាយ ផ្ទាំងយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្ម ផ្ទាំងសញ្ញា ត្រូវកែលំអរឱ្យបានសមស្របតាមប្រកាសនេះ។

**ប្រការ ៥.-**

រាជធានីភ្នំពេញ ខេត្តសៀមរាប និង ក្រុងព្រះសីហនុ ត្រូវអនុវត្តជាបន្ទាន់នូវកិច្ចការនេះឱ្យបាន

ចប់ជាស្ថាពរ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០២។

**ប្រការ ៦.-**

ខេត្ត-ក្រុង ទូទាំងព្រះរាជាណាចក្រកម្ពុជាដែលពុំមានចែងក្នុងប្រការ ៥ ត្រូវអនុវត្តកិច្ចការនេះឱ្យបានចប់ជាស្ថាពរនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០២។

**ប្រការ ៧.-**

មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្ត-ក្រុង ទទួលរូបភាព និង ខ្លឹមសារ ត្រូវសហការជាមួយអាជ្ញាធរដែនដី និង អង្គភាពជំនាញពាក់ព័ន្ធ ដើម្បីអនុវត្តតាមប្រកាសនេះឱ្យទទួលបានលទ្ធផលល្អ។

**ប្រការ ៨.-**

គ្រប់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្ត-ក្រុង ត្រូវធ្វើរបាយការណ៍ជារៀងរាល់ខែអំពីលទ្ធផលនៃការអនុវត្តន៍តាមប្រកាសនេះផ្ញើមកក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដើម្បីបូកសរុបរាយការណ៍ជូនរាជរដ្ឋាភិបាល។

**ប្រការ ៩.-**

ខុទ្ទកាល័យរដ្ឋមន្ត្រី អធិការដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ និង គ្រប់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្ត-ក្រុង មានភារកិច្ចអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០២

**រដ្ឋមន្ត្រី**

**នរោត្តម បុប្ផាទេវី**

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់សាលាខេត្ត-ក្រុង

-ដូចប្រការ៩
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

# សេចក្តីណែនាំ
## អនុវត្តខ្លឹមសារប្រកាសលេខ ១៧២ ប្រក ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០០២ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ស្តីពីការដាក់តាំងផ្ទាំងយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្ម ផ្ទាំងសញ្ញា

ក្នុងទិសដៅពង្រឹងការអនុវត្ត ការដាក់តាំងផ្ទាំងយីហោ ផ្ទាំងផ្សាយពាណិកម្ម និង ផ្ទាំងសញ្ញា ឱ្យបានត្រឹមត្រូវ និង ប្រកបដោយសណ្តាប់ធ្នាប់សំដៅលើកតម្កើង សោភ័ណភាព កិត្យានុភាពជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ សូមធ្វើការណែនាំដូចខាងក្រោម ៖

១-គ្រប់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី និងខេត្ត ត្រូវធានាឲ្យបាននូវការរក្សាការពារអក្សរសាស្ត្រខ្មែរ តាមរយៈការអនុវត្តនូវការសរសេរលើ ផ្ទាំងយីហោ ផ្ទាំងផ្សាយពាណិកម្ម និង ផ្ទាំងសញ្ញា ទៅតាមមូលដ្ឋានរៀងៗខ្លួន ដោយកំណត់ឱ្យបានច្បាស់អំពីរបៀបសរសេរអក្សរ ទំហំអក្សរ អក្សរជាតិ អក្សរបរទេស នាម និង ពាណិជ្ជនាម ឱ្យបានត្រឹមត្រូវតាមខ្លឹមសារប្រកាសលេខ ១៧២ ប្រក ចុះថ្ងៃទី១២ ខែ កក្កដា ឆ្នាំ២០០២ របស់ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ។

២-របៀបសរសេរលើផ្ទាំងយីហោ ផ្ទាំងផ្សាយពាណិកម្ម និងផ្ទាំងសញ្ញា ត្រូវកំណត់យកអក្សរខ្មែរជាធំ លើកលែងតែ ពាណិជ្ជនាម ដែលអនុញ្ញាតឱ្យសរសេរជាអក្សរបរទេសបាន នៅលើផ្ទាំងដាច់តែឯង តែត្រូវពិនិត្យការទទួលបានសិទ្ធិពាណិជ្ជនាម ដែលបានចុះបញ្ជី និង អនុញ្ញាតដោយ

ក្រសួងពាណិជ្ជកម្ម មុនផ្តល់ការអនុញ្ញាតឱ្យដាក់តាំងផ្សព្វផ្សាយជាសាធារណៈ។ ករណីនេះ មិនអនុញ្ញាតឲ្យសរសេរពាណិជ្ជនាមជាអក្សរខ្មែរ តូចជាងអក្សរបរទេសដាក់នៅពីក្រោមនោះទេ។

៣-គ្រប់ផ្ទាំងយីហោ ផ្ទាំងផ្សាយពាណិកម្ម និង ផ្ទាំងសញ្ញា អាចសរសេរឈ្មោះក្រុមហ៊ុន និងពាណិជ្ជនាម មានទំហំស្មើគ្នាបាន តែបើចង់សរសេរអក្សរបរទេសបន្ថែមពីក្រោមត្រូវមានទំហំពាក់កណ្តាលនៃអក្សរ ខ្មែរ។

៤-គ្រប់ផ្ទាំងយីហោ ផ្សាយពាណិជ្ជកម្ម និង ផ្ទាំងសញ្ញា ដែលមានខ្លឹមសារជាភាសាបរទេស ហើយអាចបកប្រែជា ភាសាខ្មែរបាន ត្រូវសរសេរខ្លឹមសារនោះជាភាសារខ្មែរវិញដូចជា ផ្ទះលក់វត្ថុអនុស្សាវរីយ៍ Souvenir Shop មិនមែន **ស៊ូវីនាសប់** ទេ។

៥-គ្រប់ផ្ទាំងយីហោ ផ្សាយពាណិជ្ជកម្ម និងផ្ទាំងសញ្ញា ដែលសរសេរលេខជាបរទេស ត្រូវសរសេរជាលេខខ្មែរវិញ។

៦-ចំពោះការសរសេរអក្សរខ្មែរនៅក្នុងផ្ទាំងយីហោ ផ្សាយពាណិជ្ជកម្ម និងផ្ទាំងសញ្ញា ក្នុងខ្លឹមសារបន្ទាប់បន្សំ ដើម្បីប្រាប់ពីគោលដៅពាណិជ្ជកម្ម ពីអាសយដ្ឋាន ទំហំអក្សរនោះមិនពាក់ព័ន្ធនិងចំណុចណែនាំទី២ នោះឡើយ។

៧-រាល់ការបោះផ្សព្វផ្សាយ អក្សរ ពាក្យស្លោក ជាអក្សរជាតិ ឬ បរទេស និងរូបភាពផ្សេងៗលើផលិតផលសម្លៀកបំពាក់ និងសម្ភារៈប្រើប្រាស់ផ្សេងៗ ត្រូវឆ្លងការពិនិត្យខ្លឹមសារជាមុនជៀសវាងការប៉ះពាល់ដល់ការការពារកម្មសិទ្ធិបញ្ញា សណ្តាប់ធ្នាប់សាធារណៈ និងសីលធម៌សង្គម។

៨-រាល់ការដាក់តាំងផ្ទាំងយីហោ ផ្សាយពាណិជ្ជកម្ម និងផ្ទាំងសញ្ញា បដា ប័ណ្ណប្រកាសផ្សេងៗ សម្រាប់ផ្សព្វផ្សាយធ្វើ អាជីវកម្ម សេវាកម្ម ឬ ផលិតកម្ម ត្រូវសុំការអនុញ្ញាតពីមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ រាជធានីខេត្ត ឬ ខណ្ឌ ស្រុក គោលដៅ។

៩-រាល់ការអនុញ្ញាតត្រូវមានកម្រៃសេវាកម្ម ដែលកំណត់ដោយប្រកាសរួមរបស់ក្រសួងវប្បធម៌និង វិចិត្រសិល្បៈ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬតាមតារាងកម្រៃសេវាកម្មរបស់ការិយាល័យច្រកចេញចូលតែមួយ នៃ ខណ្ឌ ស្រុក គោលដៅ ដែលទទួលបានការធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចពី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ។

ក្រសួង សង្ឃឹម និងជឿជាក់ថា លោក លោកស្រីជាថ្នាក់ដឹកនាំគ្រប់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ រាជធានី/ខេត្ត នឹងចាត់ចែងអនុវត្តតាមខ្លឹមសារសេចក្តីណែនាំនេះ ប្រកបដោយប្រសិទ្ធិភាពខ្ពស់។

**រដ្ឋមន្ត្រី**

**កន្លែងទទួល៖**

-ក្រសួងមហាផ្ទៃ

-គ្រប់សាលារាជធានី/ខេត្ត

-មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ រាជធានី/ខេត្ត

-ឯកសារ-កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

លេខ ៖ ២៦៣ ប្រក

# ប្រ កា ស
## ស្តីពី
## ការធ្វើប្រតិភូកម្មមុខងារ និង ភារកិច្ច ការងារវប្បធម៌ និង វិចិត្រសិល្បៈ ជូន ក្រុង ស្រុក គោលដៅ

## រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល

- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញសេចក្តីសំរេច លេខ១២ សសរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតការិយាល័យច្រកចេញ-ចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ នៅថ្នាក់ស្រុក ខណ្ឌ

## សម្រេច

**ប្រការ ១.-**

ត្រូវបានធ្វើប្រតិភូកម្មមុខងារ និង ភារកិច្ចការងារវប្បធម៌ និង វិចិត្រសិល្បៈ ជូន ក្រុង ស្រុកគោលដៅក្នុងក្របខណ្ឌនៃការចេញអាជ្ញាប័ណ្ណ ដើម្បីផ្តល់សេវាកម្មវប្បធម៌ និង វិចិត្រសិល្បៈ ដូចខាងក្រោម ៖

- កម្មវិធីសម្តែងផ្សេងៗ (ក្រៅផ្លូវការ)
- ការបញ្ចាំងភាពយន្ត និង វីដេអូ
- អាជីវកម្ម លក់ដូល ស្នាដៃភាពយន្ត វីដេអូ
- ផ្លាកសញ្ញាអាជីវកម្មផ្សេងៗ
- អាជីវកម្មគ្រឿងបំពងសម្លេង
- អាជីវកម្មលក់ ដូល សៀវភៅ
- អាជីវកម្មសិល្បៈសូនរូប
- អាជីវកម្មថតរូប
- អាជីវកម្មកាត់សក់ អ៊ុតសក់ លំអក្រចក និង សំអាងការ

**ប្រការ ២.-**

មន្ត្រីទទួលបន្ទុកការងារបច្ចេកទេសវប្បធម៌ ត្រូវរៀបចំគំរូបែបបទផ្សេងៗ រួមទាំងឯកសារពាក់ព័ន្ធនានាសម្រាប់ការចេញអាជ្ញាប័ណ្ណទៅតាមការកំណត់ដូចមានចែងនៅក្នុងប្រការ១។

**ប្រការ ៣.-**

ការអនុវត្តលើគំរូបែបបទផ្សេងៗ ដែលពាក់ព័ន្ធដល់ការចេញអាជ្ញាប័ណ្ណវប្បធម៌ របស់មន្ត្រីជំនួយការអភិបាលក្រុង ស្រុកគោលដៅ ត្រូវកំណត់ដោយសេចក្តីណែនាំមួយដោយឡែករបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ។

បញ្ជីលម្អិតរាយមុខសេវាកម្មវប្បធម៌ និង វិចិត្រសិល្បៈ ដែលត្រូវធ្វើប្រតិភូកម្ម ជូន ក្រុង ស្រុក

គោលដៅ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៤.-**

ក្រុង ស្រុក គោលដៅ ត្រូវធ្វើរបាយការណ៍អំពីស្ថិតិនៃការផ្តល់អាជ្ញាប័ណ្ណសេវាកម្មវប្បធម៌ និង វិចិត្រសិល្បៈ ជារៀងរាល់ខែ តាមរយៈមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្ត មកក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ។

**ប្រការ ៥.-**

ខុទ្ទកាល័យ អធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ អគ្គនាយកដ្ឋានបេតិកភណ្ឌ ប្រធាននាយកដ្ឋានពាក់ព័ន្ធ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈរាជធានី-ខេត្ត គោលដៅ និង មន្ត្រីទទួលបន្ទុកការងារវិសហមជ្ឈការ មានភារកិច្ចអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហស្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៩

**រ ដ្ឋ ម ន្ត្រី**

**ហ៊ឹម ឆែម**

**<u>ចម្លងជូន</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងមហាផ្ទៃ
-សាលាខេត្តគោលដៅ
-ដូចប្រការ៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ** រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០

លេខ ៖ ២៧២ ប្រក

# ប្រកាស
# ស្តីពី
# ក្រមសីលធម៌របស់មត៌កមនុស្សរស់

## រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០២១០/១៦៣ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីប្រព័ន្ធមត៌កមនុស្សរស់នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- តាមការចាំបាច់របស់ក្រសួង។

## សម្រេច

## ផ្នែកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលដៅកំណត់អំពីក្រមសីលធម៌របស់មត៌កមនុស្សរស់ ក្នុងគោលបំណងលើកកម្ពស់អត្តចរិត សីលធម៌ សេចក្តីថ្លៃថ្នូរ និង កិត្តិយស ក្នុងក្របខណ្ឌវិជ្ជាជីវៈមត៌កមនុស្សរស់ ដើម្បីថែរក្សា ការពារបេតិកភណ្ឌវប្បធម៌អរូបីរបស់ជាតិឲ្យបានគង់វង្ស។

**ប្រការ ២.-**

ប្រកាសនេះ មានវិសាលភាពគ្របដណ្តប់លើពលរដ្ឋខ្មែរទូទៅ ដែលត្រូវបានជ្រើសរើស និង ទទួលស្គាល់ជាមត៌កមនុស្សរស់ក្នុងព្រះរាជាណាចក្រកម្ពុជា។

## ផ្នែកទី២

## គោលការណ៍គ្រឹះ

**ប្រការ ៣.-**

ក្រមសីលធម៌នេះ កំណត់នូវគោលការណ៍គ្រឹះសំខាន់ ៣ សម្រាប់មត៌កមនុស្សរស់អនុវត្ត ៖

- មត៌កមនុស្សរស់ត្រូវប្រកាន់ខ្ជាប់នូវវិន័យក្នុងការប្រកបមុខរបរវិជ្ជាជីវៈ
- មត៌កមនុស្សរស់ត្រូវគោរពលក្ខខណ្ឌដែលកំណត់ដោយច្បាប់ និង បទប្បញ្ញត្តិនានា ដើម្បីផលប្រយោជន៍សង្គមនិងរក្សាឲ្យបាននូវអត្តសញ្ញាណជាតិ
- មត៌កមនុស្សរស់ ត្រូវប្រកាន់ខ្ជាប់នូវឥស្សរភាពនៃវិជ្ជាជីវៈដែលមានជាអាទិ៍ ៖ ឯករាជ្យ សន្តិភាព សេរីភាព និងឧត្តមភាព ក្នុងការបំពេញវិជ្ជាជីវៈរបស់ខ្លួនដើម្បីរក្សាឲ្យបាននូវកិត្យានុភាពវប្បធម៌ជាតិ ។

## ផ្នែកទី៣

## ករណីយកិច្ចរបស់មត៌កមនុស្សរស់

**ប្រការ ៤.-**

មត៌កមនុស្សរស់ត្រូវរក្សាឲ្យបាននូវតម្លៃសីលធម៌ វិន័យការងារ គោរពច្បាប់ និង កាតព្វកិច្ចដែលត្រូវបំពេញឲ្យបានស័ក្តិសមទៅនឹងកិត្តិយសដែលទទួលបាន។

ប្រការ ៥.-

មត៌កមនុស្សរស់ ត្រូវហ៊ានលះបង់ប្តូរផ្តាច់ដើម្បីថែរក្សា ការពារនូវ ចំណេះដឹង ជំនាញ ទេពកោសល្យ បច្ចេកទេសរបស់ខ្លួនមិនឲ្យបាត់បង់ ទោះក្នុងស្ថានភាពលំបាកបែបណាក៏ដោយ។

ប្រការ ៦.-

មត៌កមនុស្សរស់ត្រូវយកអស់កម្លាំងកាយចិត្ត និង ប្រាជ្ញា ដើម្បីផ្សព្វផ្សាយ និង បណ្តុះបណ្តាលចំណេះជំនាញរបស់ខ្លួនដល់អ្នកបន្តវេនដោយឥតលាក់លៀម។

ប្រការ ៧.-

មត៌កមនុស្សរស់ត្រូវប្តូរផ្តាច់ចងក្រង ស្នាដៃ ក្បួនច្បាប់ ចំណេះជំនាញ ជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សម្រាប់រក្សាទុកជាកេរ្តិ៍មត៌កជាតិ ហើយស្នាដៃនោះត្រូវបានការពារដោយច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល។

ប្រការ ៨.-

មត៌កមនុស្សរស់ត្រូវរក្សាទំនាក់ទំនងសាមគ្គីភាពល្អនិងត្រូវធ្វើជាគំរូក្នុងឥរិយាបថ អាកប្បកិរិយា និងពាក្យសម្តីជាមួយគ្រប់មជ្ឈដ្ឋាន។

ប្រការ ៩.-

មត៌កមនុស្សរស់ ត្រូវគោរពតាមកាតព្វកិច្ចរបស់ខ្លួន ដែលមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២១០/១៦៣ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីប្រព័ន្ធមត៌កមនុស្សរស់ នៃព្រះរាជាណាចក្រកម្ពុជា និង តាមគោលការណ៍កំណត់នៃក្រមសីលធម៌វិជ្ជាជីវៈសិល្បករ។

ប្រការ ១០.-

មត៌កមនុស្សរស់មិនត្រូវយកគោរមងារ និង ភាពល្បីល្បាញរបស់ខ្លួនទៅគាបសង្កត់ ឬ បង្កើតបញ្ហាអ្វីមួយដល់អ្នកដទៃ និង សង្គមជាតិ។

## ផ្នែកទី៤

## អវសានប្បញ្ញត្តិ

ប្រការ ១១.-

បុគ្គល ឬ ក្រុម ដែលបានទទួលគោរមងារជាមត៌កមនុស្សរស់ មានភារកិច្ចត្រូវគោរពក្រមសីលធម៌វិជ្ជាជីវៈនេះ។

ប្រការ ១២.-

នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ អគ្គនាយកបេតិកភណ្ឌ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ គ្រប់ប្រធាននាយកដ្ឋានអង្គភាពពាក់ព័ន្ធ ប្រធានមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ រាជធានី-ខេត្ត និង ប្រធានគណៈកម្មការមេត៌កមនុស្សរស់ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ហ៊ឹម ឆែម**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង-ស្ថាប័ន

-ដូចប្រការ១២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**
លេខ ៖ ៣៧ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២

# ប្រកាស
# ស្តីពី
# ការធ្វើប្រតិភូកម្មមុខងារ និង ភារកិច្ចការងារវប្បធម៌ និង វិចិត្រសិល្បៈ ជូនខណ្ឌគោលដៅនៃរាជធានីភ្នំពេញ

## រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញសេចក្តីសម្រេចលេខ ១២ សសរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និង ការិយាល័យប្រជាពលរដ្ឋ

នៅថ្នាក់ស្រុក/ខណ្ឌ។

## សម្រេច

**ប្រការ ១.-**

ត្រូវបានធ្វើប្រតិភូកម្មមុខងារនិងភារកិច្ចការងារវប្បធម៌ និង វិចិត្រសិល្បៈ ជូនខណ្ឌគោលដៅនៃរាជធានីភ្នំពេញក្នុងក្របខណ្ឌនៃការចេញអាជ្ញាបណ្ណ ដើម្បីផ្តល់សេវាកម្មវប្បធម៌ និង វិចិត្រសិល្បៈ ដូចខាងក្រោម៖

- កម្មវិធីសម្តែងសិល្បៈផ្សេងៗ
- កម្មវិធីបញ្ចាំងភាពយន្ត វីដេអូ
- សេវាកម្មលក់ ជួលស្នាដៃភាពយន្ត វីដេអូ
- សេវាកម្មផ្តិតរូប ថតរូប ថតវីដេអូ
- សេវាកម្មស្លាកសញ្ញាអាជីវកម្ម
- សេវាកម្មចម្លាក់ពុម្ព
- សេវាកម្មលក់សៀវភៅ
- សេវាកម្មបញ្ចូលបទភ្លេងទូរស័ព្ទ
- សេវាកម្មគ្រឿងបំពងសំឡេង
- សេវាកម្មអ៊ុតសក់ កាត់សក់ លម្អក្រចក និង
- សេវាកម្មសម្អាងការ

**ប្រការ ២.-**

មន្ត្រីទទួលបន្ទុកបច្ចេកទេសជំនាញនិងនីតិកម្ម ត្រូវរៀបចំគំរូសំណុំបែបបទ តាមគោលការណ៍កំណត់ជូនខណ្ឌគោលដៅសម្រាប់ការផ្តល់អាជ្ញាប័ណ្ណសេវាកម្ម ដូចបានចែងក្នុងប្រការ១។

**ប្រការ ៣.-**

ការអនុវត្តលើសំណុំបែបបទ ដែលពាក់ព័ន្ធដល់ការចេញអាជ្ញាប័ណ្ណសេវាកម្ម វប្បធម៌ និងវិចិត្រសិល្បៈ ត្រូវកំណត់ដោយសេចក្តីណែនាំមួយដោយឡែករបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ។

បញ្ជីលម្អិតរាយមុខសេវាកម្ម ដែលត្រូវធ្វើប្រតិភូកម្មជូនខណ្ឌគោលដៅនៃរាជធានីភ្នំពេញ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៤.-**

ខណ្ឌ គោលដៅ ត្រូវធ្វើរបាយការណ៍រៀងរាល់ខែ និង ឆ្នាំ ពីលទ្ធផលនៃសកម្មភាពផ្តល់អាជ្ញាប័ណ្ណសេវាកម្ម វប្បធម៌ និង វិចិត្រសិល្បៈ តាមរយៈមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈរាជធានី មកក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ។

**ប្រការ ៥.-**

នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈរាជធានីភ្នំពេញ និង មន្ត្រីទទួលបន្ទុកការងារវិសហមជ្ឈការ មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ហ៊ឹម ឆែម**

**កន្លែងទទួល ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
(ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល)
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងមហាផ្ទៃ
(អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន)
-សាលារាជធានីភ្នំពេញ
-ដូចប្រការ៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# សេចក្តីណែនាំ
## អនុវត្តខ្លឹមសារប្រកាសលេខ ៣៧ប្រក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ ២០១២ ស្តីពីការធ្វើប្រតិភូកម្មមុខងារ និង ភារកិច្ចការងារវប្បធម៌ និង វិចិត្រសិល្បៈ ជូនខណ្ឌគោលដៅនៃរាជធានីភ្នំពេញ

ផ្អែកលើខ្លឹមសារសេចក្តីសម្រេចលេខ១២សសរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និង ការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក-ខណ្ឌ ។

ដើម្បីជានាឲ្យបាននូវប្រសិទ្ធភាព និង លក្ខខណ្ឌចាំបាច់នៃការងារគ្រប់គ្រង និង ការអនុវត្តតាមខ្លឹមសារ ប្រកាសលេខ ៣៧ប្រក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២ ស្តីពីការធ្វើប្រតិភូកម្មមុខងារ និង ភារកិច្ចការងារវប្បធម៌ និង វិចិត្រសិល្បៈ ជូនខណ្ឌគោលដៅនៃរាជធានីភ្នំពេញ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ សូមធ្វើការណែនាំដូចខាងក្រោម ៖

### ក. <u>អំពីបែបបទនៃការស្នើសុំសេវាកម្ម</u>

អតិថិជនដែលមានបំណងប្រកបអាជីវកម្ម សេវាកម្មវប្បធម៌ និង វិចិត្រសិល្បៈ ត្រូវបំពេញសំណុំបែបបទដូចខាងក្រោម ៖

- ពាក្យស្នើសុំ (មានបិទតែមប្រើយ៍) ............ ១ ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ច្បាប់ចម្លង) ............ ១ ច្បាប់
- កិច្ចសន្យា ............ ១ ច្បាប់
- ប្លង់បង្ហាញទីតាំងអាជីវកម្ម ............ ១ ច្បាប់
- រូបថត ទំហំ ៣ x ៤ ............ ៣ សន្លឹក
- បង្កាន់ដៃបង់ប្រាក់ ............ ១ ច្បាប់

ចំពោះការសុំអនុញ្ញាតប្រកបអាជីវកម្មបន្ត ទម្រង់បែបបទនេះត្រូវកាត់បន្ថយមកត្រឹម ៖

- ពាក្យស្នើសុំបន្ត ............ ១ ច្បាប់

- កិច្ចសន្យា ........................................................................................................ ១ ច្បាប់
- រូបថត ទំហំ ៣ x ៤ ........................................................................................ ២ សន្លឹក
- បង្កាន់ដៃបង់ប្រាក់ .............................................................................................. ១ ច្បាប់

## ខ. សេវាកម្មដែលត្រូវចេញលិខិតអនុញ្ញាត( សម្រាប់រយៈពេលខ្លី )

១. ការប្រគំតន្ត្រីតាមទីសាធារណៈ

២. ការសម្តែងល្ខោនគ្រប់ទម្រង់( លក់សំបុត្រ )

៣. អាជីវកម្មរាំលក់ផ្កា

៤. បញ្ចាំងភាពយន្តវីដេអូផ្សាយពាណិជ្ជកម្ម

៥. បញ្ចាំងភាពយន្តវីដេអូកំដរក្នុងពិធីបុណ្យផ្សេងៗ

៦. បដាផ្សាយពាណិជ្ជកម្ម

៧. ប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្ម

## គ. សេវាកម្មដែលត្រូវចេញប័ណ្ណអនុញ្ញាត (សម្រាប់រយៈពេលវែង)

១. បញ្ចាំងភាពយន្តវីដេអូកំដរភ្ញៀវ

២. អគារលក់ស៊ីឌី វីស៊ីឌី ឌីវីឌី

៣. ហាងលក់ ជួលកាសែ្សត ស៊ីឌី វីស៊ីឌី ឌីវីឌី

៤. តូបលក់ជួលកាសែ្សត ស៊ីឌី វីស៊ីឌី ឌីវីឌី

៥. អគារផ្តិតរូប ថតរូប ថតវីដេអូ (ស្ទូឌីយោ)

៦. ហាងថតរូប ថតវីដេអូ

៧. ផ្ទាំងយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្ម និង និមិត្តសញ្ញាផ្សេងៗ

៨. ទីតាំងផលិតស្លាកសញ្ញា

៩. ដាងគំនូរ

១០. ទីតាំងផលិត លក់ចម្លាក់ពុម្ពស៊ីម៉ង់

១១. ទីតាំងកម្មផលិត លក់ចម្លាក់ម្ជាងសិលា

១២. បណ្ណាគារ និងតូបលក់សៀវភៅ

១៣.សេវាកម្មបញ្ចូលបទភ្លេងទូរស័ព្ទ

១៤.សេវាកម្មជួលឧគ្ឃោសនស័ព្ទក្នុងពិធីផ្សេងៗ

១៥.សេវាកម្មជួលធុងបាស់

១៦.សេវាកម្មកាត់សក់

១៧.សេវាកម្មអ៊ុតសក់ កាត់សក់ លម្អក្រចក

១៨.សេវាកម្មសម្អាងការ

## ឃ. គោលការណ៍ត្រួតពិនិត្យ

### ឃ១.ផ្នែកសិល្បៈទស្សនីយភាព

- ខ្លឹមសារ សិល្បៈដែលយកមកប្រគំឬសម្តែងត្រូវសមស្របទៅនិងគោលនយោបាយវប្បធម៌ជាតិ
- រូបភាពនិងទម្រង់សិល្បៈរបស់ជាតិ មិនត្រូវកែច្នៃខុសពីលំនាំដើម
- រាល់ការប្រគុំ ឬ សម្តែងរបស់ក្រុមសិល្បៈបរទេស ត្រូវមានការអនុញ្ញាតពីក្រសួង ឬ ពីមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ
- ការប្រគុំ ឬសម្តែងដែលមានទិសដៅអប់រំ បំផុសចំណេះដឹងល្អដល់ប្រជាពលរដ្ឋ ត្រូវទទួលបានការលើកទឹកចិត្ត
- ការលួចយកស្នាដៃអ្នកដទៃមកសម្តែងត្រូវហាមឃាត់។

### ឃ២.ផ្នែកស្នាដៃភាពយន្តវីដេអូ និងថតរូប

- គ្រប់ស្នាដៃភាពយន្ត វីដេអូ ជាកាសែ្សត ស៊ីឌី ឌីវីឌី ដែលធ្វើអាជីវកម្ម ឬ ផ្សព្វផ្សាយត្រូវមានទិដ្ឋាការអនុញ្ញាតពីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- ការប្រើប្រាស់បច្ចេកវិទ្យាកាត់តរូបភាពក្នុងគោលបំណងទុច្ចរិតត្រូវហាមឃាត់
- ហាមការផ្សព្វផ្សាយរូបភាពអាសអាភាស ឬ រូបភាពអ្វីមួយៗដែលច្បាប់ហាមឃាត់
- មិនត្រូវយករូបថតអតិថិជនទៅធ្វើអាជីវកម្ម ឬ សេវាកម្មដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ

### ឃ៣.ផ្នែកស្លាកសញ្ញាអាជីវកម្ម

- អក្សរខ្មែរត្រូវគោរពតាមពាក្យពេចន៍ និង អក្ខរាវិរុទ្ធ ក្នុងវចនានុក្រមរបស់សម្តេចព្រះមហា

សុមេជាធិបតី ជោតញ្ញាណោ **ជួន ណាត**

- ទំហំអក្សរខ្មែរត្រូវសរសេរធំជាងអក្សរបរទេស ហើយដាក់ជួរលើគេបង្អស់
- អក្សរបរទេសត្រូវសរសេរពីក្រោម និង មានទំហំពាក់កណ្តាលនៃអក្សរខ្មែរ ហើយពាក្យពេចន៍ និងអក្ខរាវិរុទ្ធនៃអក្សរបរទេស ក៏ត្រូវសរសេរឲ្យបានត្រឹមត្រូវតាមភាសាជាតិនីមួយៗ
- ពាណិជ្ជនាមអាចសរសេរជាអក្សរបរទេសបាន តែមិនអនុញ្ញាតឲ្យសរសេរលើអក្សរ ខ្មែរទំហំធំជាង (ន័យដូចគ្នា) លើផ្ទាំងជាមួយ។
- រូបភាពផ្ទាំងឃីហោ ផ្ទាំងផ្សាយពាណិជ្ជកម្ម ផ្ទាំងសញ្ញា និង និមិត្តសញ្ញាគ្រប់ប្រភេទ ត្រូវរក្សាឲ្យបាននូវសោភ័ណភាព។

## ឃ៤. <u>ផ្នែកចម្លាក់ពុម្ពស៊ីម៉ង់និងម្នាងសិលា</u>

- រាល់ក្បាច់ចម្លាក់ត្រូវគោរពឲ្យបានតាមបទដ្ឋានបច្ចេកទេសមានរចនាបថនិងខ្នាតរបស់ជាតិ
- រាល់ស្នាដៃត្រូវមានចារិកសម្គាល់ពីប្រភពផលិត
- មិនត្រូវក្លែងបន្លំ លក់វត្ថុបុរាណដែលជាបេតិកភ័ណជាតិ
- មិនត្រូវយកវត្ថុបុរាណមកដាក់តាំងលាយឡំជាមួយផលិតផលថ្មី។

## ឃ៥.<u>ផ្នែក អភិវឌ្ឍន៍វប្បធម៌</u>

- ត្រូវធានាសុវត្ថិភាពអតិថិជនក្នុងការប្រើប្រាស់ឧបករណ៏ សម្ភារៈនិងសារធាតុគីមីផ្សេងៗ
- ការតុបតែងសម្លៀកបំពាក់ និង គ្រឿងអលង្ការប្រពៃណី ឬ បុរាណត្រូវគោរពតាមលក្ខណៈទម្រង់ដើមរបស់ជាតិ
- ក្នុងពិធីនីមួយៗ មិនត្រូវបំពងសម្លេងគ្រឿងឧឃ្លោសនស័ព្ទខ្លាំងហួស ដែលធ្វើឲ្យរំខានដល់ការរស់នៅនិងបរិស្ថានដែលនៅជុំវិញ ពិសេសក្នុងពេលយប់។

## ឃ៦.<u>ផ្នែកសៀវភៅ</u>

- សៀវភៅគ្រប់ប្រភេទដែលយកមកដាក់លក់ គឺជាសៀវភៅដែលមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ឬ ពីស្ថាប័នមានសមត្ថកិច្ចដែលច្បាប់កំណត់ និង ដោយមានការចុះបញ្ជីត្រឹមត្រូវ
- សៀវភៅលួចចម្លងគ្រប់ប្រភេទជាភាសាខ្មែរ ឬ បរទេស មិនអនុញ្ញាតឲ្យដាក់លក់។

ខ្លឹមសារគោលការណ៍ត្រួតពិនិត្យខាងលើនេះ ត្រូវដាក់បញ្ចូលក្នុងកិច្ចសន្យានៃទម្រង់បែបបទស្នើសុំសេវាកម្មរបស់អតិថិជន ។

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ សង្ឃឹមនិងជឿជាក់ថា មន្ត្រីទទួលខុសត្រូវគ្រប់លំដាប់ថ្នាក់នៅគ្រប់ខណ្ឌគោលដៅនៃរាជធានីភ្នំពេញ រួមទាំងអតិថិជន នឹង ចូលរួមអនុវត្តតាមខ្លឹមសារសេចក្តីណែនាំនេះដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងទិសដៅលើកស្ទួយប្រព័ន្ធរដ្ឋបាលថ្មីឲ្យទទួលបានជោគជ័យ។

**រដ្ឋមន្ត្រី**

**<u>កន្លែងទទួល</u>**

-ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

-ក្រសួងមហាផ្ទៃ

(អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន)

-សាលារាជធានីភ្នំពេញ

-មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ រាជធានីភ្នំពេញ

-សាលាខណ្ឌគោលដៅ

-ឯកសារ-កាលប្បវត្តិ